Fact Sheet 4 – Khmer

សន្លឹកហេតុការណ៍ 4

ការលើកកម្ពស់សមភាពយេនឌ័រ និងការគោរព

មានកិច្ចការជាច្រើនដែលអ្នកអាចធ្វើបាន ដើម្បីតទល់នឹងជំនឿដែលបង្កអន្តរាយ និងទប់ស្កាត់អាកប្បកិរិយា និងការរំលោភបំពានមិនសមរម្យចំពោះស្ត្រី។

កិច្ចការទាំងនេះរួមមាន៖

បង្កើតការយល់ដឹង៖ កង្វះព័ត៌មាន និងព័ត៌មានមិនពិតអំពីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ក្នុងគ្រួសារ និងផ្លូវភេទ (DFSV) និងបុព្វហេតុរបស់វាបង្កើតឱ្យមានការភ័យខ្លាច និងទប់ស្កាត់ស្ត្រីដែលទទួលរងនូវអំពើហិង្សា និងការរំលោភបំពានពីការស្វែងរកបានជំនួយ។ អ្នកដឹកនាំជំនឿសាសនា និងសហគមន៍អាចធ្វើការបណ្តុះបណ្តាលជាក់លាក់ដើម្បីយល់ដឹងកាន់តែច្បាស់អំពី DFSV និងវិធីបង្ការវា។ អ្នកអាចបញ្ចូលព័ត៌មានពីសន្លឹកហេតុការណ៍ នៅក្នុងព្រឹត្តិប័ត្រសហគមន៍ ឬចែកចាយសន្លឹកហេតុការណ៍ទាំងនេះ ជាប័ណ្ណផ្សព្វផ្សាយព័ត៌មាន។ បង្ហាញផ្ទាំងរូបភាពដើម្បីបង្កើនចំណេះដឹងសហគមន៍ ឬបង្កើតសេចក្តីប្រកាស ដើម្បីឱ្យសហគមន៍របស់អ្នកដឹងពីជំហរដែលអ្នកលើកកម្ពស់ការប្រើអាកប្បកិរិយាប្រកបដោយសុវត្ថិភាព និងការគោរពរបស់បុរសក្នុងទំនាក់ទំនង និងសិទ្ធិរបស់ស្ត្រីក្នុងការរស់នៅរួចផុតពីអំពើហិង្សា និងការរំលោភបំពាន។

មានការពិភាក្សា៖ បង្កើតឱកាសនានាដើម្បីនិយាយអំពី DFSV និងសារៈសំខាន់នៃសមភាពយេនឌ័រ ក្នុងការបង្ការការប្រើអំពើហិង្សាប្រឆាំងនឹងស្ត្រី។ នេះប្រហែលជាតាមរយៈសេចក្តីអធិប្បាយការពិភាក្សាក្រុមតូចមិនជាផ្លូវការ ឬដោយការអញ្ជើញអ្នកជំនាញមកនិយាយកាន់សហគមន៍របស់អ្នក។ រាប់បញ្ចូលមនុស្សគ្រប់គ្នានៅក្នុងសហគមន៍របស់អ្នក - បុរស ស្ត្រី និងយុវជន។

ពិចារណាអំពីរបៀបដែលជំនឿបូរាណរបស់អ្នក ជំរុញឱ្យមានការគោរព និងសមភាពរវាងស្ត្រី និងបុរស របៀបដែលតួនាទីរបស់ស្ត្រី ខុសគ្នាពីបុរស ហើយថាតើមានអ្វីទៀតដែលអ្នកអាចធ្វើបានដើម្បីរួមបញ្ចូលស្ត្រីក្នុងការសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ។

ទាក់ទិន៖ ចូលរួមក្នុងគំនិតផ្តួចផ្តើមសហគមន៍ដែលលើកកម្ពស់ការគោរពរវាងបុរស និងស្ត្រី រួមទាំងទិវាអន្តរជាតិប្រចាំឆ្នាំសម្រាប់ការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី នៅថ្ងៃទី២៥ ខែវិច្ឆិកា និង១៦ថ្ងៃនៃយុទ្ធនាការសកម្មនិយម ប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ។ អ្នកក៏អាចទទួលស្គាល់ទិវាស្ត្រីអន្តរជាតិផងដែរ នៅថ្ងៃទី៨ ខែមីនា ដោយអបអរសាទរការចូលរួមចំណែករបស់ស្ត្រីចំពោះជំនឿសាសនា និងសហគមន៍របស់អ្នក។

ចាត់វិធានការ៖ លើកកម្ពស់សមភាពយេនឌ័រ ដោយធ្វើការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់អ្នក ដើម្បីលើកទឹកចិត្តសមភាព និងការគោរពដល់ស្ត្រី។ ទាំងនេះអាចរួមបញ្ចូលទាំងការបង្កើតសមភាពយេនឌ័រ / ផែនការ ឬក្រុមសកម្មភាពទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី។ លើកទឹកចិត្តស្ត្រីវ័យក្មេងឱ្យចូលរួមនៅក្នុងភាពជាអ្នកដឹកនាំ និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកដឹកនាំថ្មី។

បង្កើតភាពជាដៃគូ និងតស៊ូមតិដើម្បីផ្លាស់ប្តូរ៖ ការភ្ជាប់ និងធ្វើការជាមួយក្រុមសហគមន៍ បណ្តាញ និងសហគមន៍ជំនឿសាសនាដទៃទៀត អាចជួយអ្នកឱ្យរៀនដឹង និងពង្រឹងការងាររបស់អ្នកដើម្បីបង្ការ DFSV។ នេះក៏អាចផ្តល់ឱកាសដើម្បីភ្ជាប់ជំនឿសាសនា និងសមាជិកសហគមន៍របស់អ្នកជាមួយនឹងសេវាកម្មសុវត្ថិភាពនានា និងលើកទឹកចិត្តពួកគេឱ្យស្វែងរកជំនួយ និងការគាំទ្រ។

ធនធាន DFSV

មានធនធានជាច្រើនដើម្បីជួយអ្នកក្នុងការទទួលស្គាល់ និងប្រឈមនឹងអាកប្បកិរិយាហិង្សា និងការរំលោភបំពាន។ ទាំងនេះរួមមាន៖

1800 RESPECT - សេវាកម្មប្រឹក្សាយោបល់អំពីការរំលោភបំពានលើផ្លូវភេទ អំពើហិង្សាលើដៃគូស្និទ្ធស្នាល និងក្នុងគ្រួសារថ្នាក់ជាតិ
ព័ត៌មានអំពី DFSV ជាភាសាផ្សេងៗ
Information about DFSV in different languages

Anglican Diocese Melbourne
កម្មវិធីទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី
Preventing Violence Against Women Program

គម្រោងទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងភាពជាអ្នកដឹកនាំស្ត្រី AMES
ការប្រឆាំងជំទាស់ប្រចាំថ្ងៃនឹងការរើសអើងភេទ - ផ្នែកទី១ និងទី២
Challenging Everyday Sexism – Part 1 and 2

គម្រោងប្រឆាំងជំទាស់អំពើហិង្សាក្នុងគ្រួសារ
ការលើកកម្ពស់សមភាព និងការគោរព៖ កិច្ចសហការអន្តរជំនឿលើការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
Promoting Equality and Respect: An interfaith collaboration on preventing family violence

ក្រុមជំនុំ Scotland - យុទ្ធសាស្ត្រសុចរិតភាព
ធ្វើការដើម្បីបញ្ចប់អំពើហិង្សាប្រឆាំងនឹងស្ត្រី
ធនធានសម្រាប់ដោះស្រាយអំពើហិង្សាប្រឆាំងនឹងស្ត្រី
Working to end violence against women Resources for tackling violence against women

សហគមន៍ជំនឿសាសនា ដោះស្រាយអំពើហិង្សាប្រឆាំងនឹងស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ - តើអ្វីដែលដំណើរការ៖
គន្លឹះសំខាន់ៗសម្រាប់ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនៅតាមកន្លែងជំនឿសាសនា
Key Tips for Effective Prevention in Faith Settings
សាកលវិទ្យាល័យម៉ែលបិន និងមជ្ឈមណ្ឌលពហុវប្បធម៌សម្រាប់សុខភាពស្ត្រី

មជ្ឈមណ្ឌលពហុវប្បធម៌ ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ InTouch
ការផ្តល់អំណាចដល់អ្នកដឹកនាំជំនឿសាសនា និងអ្នកដឹកនាំ សហគមន៍ ដើម្បីទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី
Empowering Faith and Community Leaders to Prevent Violence Against Women

Our Watch (ការឃ្លាំមើលរបស់យើង) - តោះនាំគ្នាផ្លាស់ប្តូរសាច់រឿង៖ អំពើហិង្សាប្រឆាំងនឹងស្ត្រីនៅប្រទេសអូស្ត្រាលី
Let's change the story: Violence against women inAustralia

Our Watch (ការឃ្លាំមើលរបស់យើង) - មគ្គុទេសក៍ការទប់ស្កាត់របស់អ្នកអនុវត្ត
Prevention Practitioner Guide
(ជាមួយឧទាហរណ៍សម្រាប់បរិបទផ្អែកលើជំនឿសាសនា)

Our Watch (ការឃ្លាំមើលរបស់យើង) - តើមានអ្វីដែលជម្រុញអំពើហិង្សាប្រឆាំងនឹងស្ត្រី?
What Drives Violence Against Women?

ការលើកកម្ពស់ទំនាក់ទំនងសមភាព និងការគោរពនៅក្នុងសហគមន៍ជំនឿសាសនា
សៀវភៅណែនាំ និងកញ្ចប់ឧបករណ៍
Manual and toolkit

SASA! ជំនឿ
មគ្គុទេសក៍សម្រាប់សហគមន៍ជំនឿសាសនា ដើម្បីទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី និងជំងឺអេដស៍
A Guide for Faith Communities to Prevent Violence Against Women and HIV
Trocaire និងការជំរឿងសម្លេង
The Man Box៖ ការសិក្សាអំពីភាពជាយុវជននៅក្នុងប្រទេសអូស្ត្រាលី
គម្រោងរបស់បុរស - សេវាកម្មសង្គម Jesuit
The Men's Project – Jesuit Social Services

ធនធាន White Ribbon Australia (ខ្សែបូពណ៌សអូស្ត្រាលី)
resources

អ្នកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់ និងដោះស្រាយ DFSV ហើយរក្សាស្ត្រីនិងកុមារឱ្យមានសុវត្ថិភាព។

ព័ត៌មានបន្ថែមមាននៅ 1800RESPECT (1800 737 732) ឬ

www.1800RESPECT.org.au

ក្នុងករណីបន្ទាន់ ឬប្រសិនបើនរណាម្នាក់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ឥឡូវនេះ សូមទូរស័ព្ទលេខ 000 ឱ្យបាន់ឆាប់ៗ។

នេះគឺជាផ្នែកមួយនៃសន្លឹកហេតុការណ៍ទាំង 4 ស្តីពី DFSV។ ព័ត៌មានបន្ថែមស្តីអំពីការលើកកម្ពស់សមភាពយេនឌ័រ និងការគោរព សូមមើលសន្លឹកហេតុការណ៍ 3។ ដើម្បីស្វែងយល់បន្ថែមអំពីការកំណត់អត្តសញ្ញាណ និងការឆ្លើយតបចំពោះ DFSV មាននៅក្នុងសន្លឹកហេតុការណ៍ 1 និង 2។

Government of South Australia
MCCSA
Multicultural Communities Council of South Australia
Women's Safety Services SA
BREAK THE CYCLE OF DOMESTIC ABUSE